00276683

C22/5/6

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-[illegible]**

| | |
|---|---|
| ដាក់ជូនទៅ | : អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទដាក់ឯកសារ | : ២២ ធ្នូ ២០០៨ |
| ភាគីអ្នកដាក់ឯកសារ | : សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី |
| ភាសាដើម | : អង់គ្លេស និងអត្ថបទបកប្រែជាភាសាខ្មែរ |
| ប្រភេទឯកសារ | : សាធារណៈ (ឯកសារដែលបានលុបចោលខ្លះ) |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
02 / 02 / 2009
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

# សេចក្តីសន្និដ្ឋានរួមរបស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីតបទៅនឹង បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្ន

---

| **ដាក់ជូនដោយ:** | **ដាក់ជូនទៅ:** |
|---|---|
| **សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី** | **អង្គបុរេជំនុំជម្រះ** |
| លោក ហុង គីមសួន | ចៅក្រម ប្រាក់ គីមសាន |
| លោក ឡោ ជុនធី | ចៅក្រម Rowan DOWNING |
| លោក នី ចាន់ឌី | ចៅក្រម ន៉ីយ ថុល |
| លោក គង់ ពិសី | ចៅក្រម Katinka LAHUIS |
| លោក យុង ផានិត | ចៅក្រម ហួត វុទ្ធី |
| លោកស្រី Silke STUDZINSKY | |
| លោក គីម ម៉េងឃី | |
| កញ្ញា ម៉ុច សុវណ្ណារី | |
| លោកស្រី Martine Jacquin | |
| លោក Philippe Cannone | |

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
02 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**មេធាវីការពារក្តីលោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. Karnavas

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

លោក តាន់ សេណារ៉ុង

លោក Anees Ahmed

ចម្លើយតបរបស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងឧទ្ធរណ៍របស់

លោក អៀង សារីប្រឆាំងនឹងការពន្យាការឃុំខ្លួនបណ្តោះអាសន្ន

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) បានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន *("ដីកាពន្យាការឃុំខ្លួន")*[1]។

២. នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ សហមេធាវីរបស់ជនជាប់ចោទបានដាក់បណ្ដឹងឧទ្ធរណ៍[2]ប្រឆាំងនឹងដីកាពន្យាការឃុំខ្លួន ព្រមទាំងបានពិភាក្សាសេចក្ដីសំអាងហេតុ នៅក្រោមវិធាន៦៣ (៣) (ក) និង (ខ) នៃវិធានផ្ទៃក្នុង *("វិធានផ្ទៃក្នុង")*។ មេធាវីការពារក្ដីបានស្នើឱ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ទុកជាមោឃៈនូវដីកាពន្យាការឃុំខ្លួន និងបង្គាប់ឱ្យមានការដោះលែងជាបណ្ដោះអាសន្ន ឬបង្គាប់ឱ្យឃុំខ្លួននៅក្នុងផ្ទះក្រោមលក្ខខណ្ឌដ៏ជាក់លាក់ ដូចមានចែងនៅក្នុងសារណារបស់ខ្លួន[3]។

៣. នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨ សារណាបណ្ដឹងឧទ្ធរណ៍ជាភាសាអង់គ្លេស និងភាសាខ្មែររបស់មេធាវីការពារក្ដី ត្រូវបានជូនដំណឹងទៅសហមេធាវីភាគីដើមបណ្ដឹងរដ្ឋប្បវេណី។

## II. សេចក្ដីសង្ខេបនៃសេចក្ដីសំអាងហេតុ

---

[1] *សំណុំរឿងរបស់អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារតុលាការ លេខ C22/4។

[2] *សំណុំរឿងរបស់អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ១៧) ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារតុលាការ លេខ C22/5/1 (*បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាពន្យាការឃុំខ្លួន*)។

[3] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាពន្យាការឃុំខ្លួន កថាខណ្ឌ៣១។

៤. ការិយាល័យសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន យ៉ាងសមស្រប និងបានបង្ហាញនូវមូលហេតុសមហេតុផល និងមាននិរន្តរភាព។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីក៏មិនបានបង្ហាញថាមានកំហុសនៅក្នុងដីកាពន្យាការឃុំខ្លួននោះក៏ទេដែរ។ ដីកាពន្យាការឃុំខ្លួនមានសំអាងហេតុ និងមានយុត្តិកម្ម។

៥. អនុលោមតាមវិធាន៦៣(៣)(ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទត្រូវបានសង្ស័យយ៉ាងខ្លាំងថា បានប្រព្រឹត្តបទល្មើស ដូចដែលបានបញ្ជាក់លំអិតនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។ ការស៊ើបសួរ កាលពីឆ្នាំមុនត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័ស និងដោយយកចិត្តទុកដាក់ ព្រមទាំងបានរកឃើញនូវភស្តុតាងថ្មីៗ។

៦. លើសពីនេះ ដីកាឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការដ៏ចាំបាច់មួយដើម្បីរាំងជនត្រូវចោទពីការជ្រៀតជ្រែកជនរងគ្រោះ និងសាក្សី ដើម្បីថែរក្សាភស្តុតាង ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ដើម្បីថែរក្សាសុវត្ថិភាពរបស់ជននោះ និងដើម្បីធានាវត្តមានរបស់ជននោះនៅក្នុងសវនាការនាពេលខាងមុខ។ ដីកានេះបានបំពេញតាមលក្ខខណ្ឌនៃវិធាន៦៣(៣)(ខ)(i-v)។

៧. ការឃុំខ្លួននៅក្នុងផ្ទះនៅក្រោមលក្ខខណ្ឌខ្លះ អាចបង្កើតឱ្យមានទម្រង់នៃការឃុំខ្លួនមួយមែន ក៏ប៉ុន្តែវាមិនអាចទប់ស្កាត់រាល់ហេតុផលទាំងអស់ដែលមានចែងនៅក្នុងវិធាន៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងបានឡើយ ជាពិសេស ហេតុផលដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ដើម្បីធានាសុវត្ថិភាពរបស់ជនជាប់ចោទ និងថែរក្សាភស្តុតាង។

## III. អង្គហេតុដែលពាក់ព័ន្ធ

៨. ក.ស.ច.ស បានដាក់សេចក្តីសំអាងហេតុចំនួន៧ទំព័រ ដែលបានបញ្ជាក់សេចក្តីសម្រេចរបស់ខ្លួនក្នុងការពន្យាការឃុំខ្លួននេះ។ ទាក់ទងនឹងវិធានផ្ទៃក្នុង ៦៣(៣)(ក)

ក.ស.ច.ស បានយោង[4] ជាសំខាន់ទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ[5] ដែលបានចេញផ្សាយសេចក្តីសម្រេចរបស់ខ្លួននាពេលថ្មីៗនេះ។ ក.ស.ច.ស បានបន្ថែមភស្តុតាងថ្មីផ្សេងទៀត បន្ទាប់ពីសេចក្តីសម្រេចរបស់អ.ប.ជ[6]។

៩. ទាក់ទងនឹងលក្ខខណ្ឌនៃវិធាន ៦៣(៣)(ខ) ក.ស.ច.ស បានគូសបញ្ជាក់ថា លក្ខខណ្ឌ ដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់អ.ប.ជ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍មិនបានផ្លាស់ប្តូរនោះទេ[7] ព្រមទាំងបានអនុម័តយកទឡ្ហីករណ៍របស់អ.ប.ជ។

១០. ជាពិសេស ក.ស.ច.ស បានធ្វើការពិចារណាអំពីរយៈពេលដែលកន្លងផុត និងបានសន្និដ្ឋានថា ការស៊ើបសួរបន្ត រួមទាំងការធ្វើសម្ភាសន៍សាក្សីច្រើនជាង១០០នាក់ រួមផ្សំទាំងភាពស្មុគស្មាញនៃសំណុំរឿងទាំងមូលរបស់ខ្លួនផង គឺសមស្របទៅនឹងលក្ខខណ្ឌនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប។

១១. លើសពីនេះ ក.ស.ច.ស បានប្រកាន់ជំហរថា ការឃុំខ្លួននៅក្នុងផ្ទះមិនមែនជាទម្រង់នៃការឃុំខ្លួនជំនួសមួយ ដ៏សមហេតុផលនោះទេ[8]។

១២. មេធាវីការពារក្តីបានអះអាង[9]ថា៖

(i) ការស៊ើបសួរមិនបានធ្វើដោយមានការយកចិត្តទុកដាក់នោះទេ

---

[4] ដីកាពន្យាការឃុំខ្លួន កថាខណ្ឌ ១១-១៧។

[5] *សំណុំរឿងរបស់អៀង សារី*
សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការឃុំខ្លួនបណ្តោះអាសន្នរបស់អៀង សារី ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ លេខ C22/I/73។

[6] សូមអានកំណត់ជើងទំព័រ១០ និង១៧ នៃដីកាពន្យាការឃុំខ្លួន មានកំណត់ហេតុសួរចម្លើយឌុច ចុះថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី១, ២ និង៣ ខែកក្កដា និងបទសម្ភាសន៍ជាមួយ Laurence Picq ចុះថ្ងៃទី២៩, ៣០ និង៣១ ខែតុលា ឆ្នាំ២០០៨។

[7] ដីកាពន្យាការឃុំខ្លួន កថាខណ្ឌ១៨-៣១

[8] ដីកាពន្យាការឃុំខ្លួន កថាខណ្ឌ៣២-៣៦

[9] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាពន្យាការឃុំខ្លួន កថាខណ្ឌ១។

(ii) ភស្តុតាងដាក់បន្ទុកជាភារកិច្ច ក.ស.ច.ស ក្នុងការបង្ហាញថា លក្ខខណ្ឌនៃវិធាន៦៣(៣)(ក) និង (ខ) ត្រូវបានបំពេញ

(iii) ក.ស.ច.ស បានខកខានមិនបានបន្ថែមភស្តុតាងដើម្បីបង្ហាញថា មានមូលដ្ឋាន ដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទអាចបានប្រព្រឹត្តបទល្មើស ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ

(iv) ការឃុំខ្លួននៅក្នុងពន្ធនាគារមិនមែនជាទម្រង់នៃការឃុំខ្លួនតែមួយគត់ និងថាការឃុំខ្លួននៅក្នុងផ្ទះក្នុងលក្ខខណ្ឌដ៏សមហេតុផល ក៏ជាជម្រើសដែល ក.ស.ច.សអាចអនុវត្តបានដែរ។

(v) ការឃុំខ្លួននៅក្នុងផ្ទះអាចការពារគោលបំណងដែលមានចែងនៅក្នុងវិធាន៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង ។

១៣ អនុលោមតាមវិធានផ្ទៃក្នុង៦៣(៣)(ក) និង(ខ) សហចៅក្រមស៊ើបអង្កេតអាចចេញដីកាឃុំខ្លួនបណ្ដោះអាសន្នចំពោះជនត្រូវចោទនៅក្រោមលក្ខខណ្ឌដូចតទៅ៖

ក. មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ចុងចោទអាចបានប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។

ខ. សហចៅក្រមស៊ើបអង្កេតពិចារណាការឃុំខ្លួនបណ្ដោះអាសន្នថាជាវិធានការចាំបាច់ក្នុង៖

(i) ការរារាំងកុំឱ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(ii) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។

(iii) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី ។

(iv) ការពារសន្តិសុខឱ្យជនត្រូវចោទ ឬ

(v) រក្សាសណ្តាប់ធ្នាប់សាធារណៈ។

១៤. វិធាន៦៣(៦)(ក) នៃវិធានផ្ទៃក្នុងចែងថា៖

ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងដូចខាងក្រោម៖ ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី១(មួយ)ឆ្នាំ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នបន្ថែមម្តងបាន១(មួយ)ឆ្នាំ។

១៥. វិធាន ៦៣(៧) នៃវិធានផ្ទៃក្នុងចែងថា៖

ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន [..]ត្រូវមានសំអាងហេតុចំពោះការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្ន។ [..]

## IV. វិសាលភាពនៃបណ្តឹងឧទ្ធរណ៍ និងតួនាទីរបស់អង្គបុរេជំនុំជម្រះ

១៦. សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញយ៉ាងទូលំទូលាយរួចទៅហើយនៅក្នុងសារណាតប[10] ចំពោះបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលបណ្តឹងឧទ្ធរណ៍នោះមានលក្ខណៈកំហិតបន្តិច។ ដូចនេះ សេចក្តីសន្និដ្ឋានទាំងនេះត្រូវបានពិគ្រោះជាឯកសារយោង។ ដូចនេះ អង្គបុរេជំនុំជម្រះអាចបដិសេធសេចក្តីសម្រេចរបស់ក.ស.ច.ស ប្រសិនបើចៅក្រមមានកំហុស និងបំពានទៅលើឆន្ទានុសិទ្ធិ និងគ្រាន់តែសង្ខេប ប្រសិនបើសេចក្តីសម្រេចនេះ "មិនមានលក្ខណៈត្រឹមត្រូវ ឬមានភស្តុតាងដែលមិនមាននិរន្តរភាព"[11]។

---

[10] *សំណុំរឿងរបស់អៀង ធីរិទ្ធ* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០២) សារណារួមរបស់សហ មេធាវីចំពោះបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ឯកសារតុលាការលេខ C20/I/17 កថាខណ្ឌ ៦-១៣។

[11] *ព្រះរាជអាជ្ញា ទល់នឹង Moinina Fofana* សំណុំរឿងលេខ SCSL-04-14-AR65 បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច បដិសេធការធានាឲ្យនៅក្រៅឃុំ ថ្ងៃទី១ ខែមិនា ២០០៥ កថាខណ្ឌ ២០។

១៧. បទដ្ឋានដូចគ្នាអាចអនុវត្តចំពោះដីកាពន្យាការឃុំខ្លួន ដែលដីកានេះត្រូវតែមានសំអាងហេតុស្របនឹងវិធាន៦៣(៧) នៃវិធានផ្ទៃក្នុង។

## V. **ឧទ្ទិសករណ៍**

វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង និងកត្តាពេលវេលា

១៨. ដីកាឃុំខ្លួនបណ្ដោះអាសន្នក៏ដូចជាដីកាពន្យាការឃុំខ្លួនតម្រូវថា៖ (i) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជនត្រូវចោទអាចបានប្រព្រឹត្តបទល្មើស ហើយចំពោះដីកាពន្យាការឃុំខ្លួនតម្រូវថា (ii) ការស៊ើបសួរត្រូវធ្វើដោយយកចិត្តទុកដាក់ និងយ៉ាងរហ័សដើម្បីធានានូវសិទ្ធិរបស់ជនត្រូវចោទក្នុងការជំនុំជម្រះដោយមិនមានការពន្យាពេលមិនសមស្រប[12]។

១៩. ដោយហេតុថា ដីកាឃុំខ្លួនបណ្ដោះអាសន្នដំបូងបានផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេតបានចេញដីកាឲ្យស៊ើបសួរជំនួសជាច្រើន ដើម្បីបង្ហាញអត្តសញ្ញាណរបស់សាក្សី បន្ទាប់មកស៊ើបសួរពួកគេ និងស្វែងរកភស្តុតាង។ (ឧ- D91 D92 D25 D40 D94 D107)។ ក.ស.ច.ស បានស៊ើបសួរសាក្សីចំនួនជាង១០០នាក់ ។

២០. ឧទាហរណ៍ ក្រៅពីការបង្កើត ស-២១ ទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗទៀតត្រូវបានគេជម្លៀស[13] សក្ខីកម្មបានបង្ហាញថា គោលនយោបាយខ្មាំង និងពន្ធនាគារនៅពាសពេញប្រទេស រួមទាំងប្រព័ន្ធជំរំអប់រំឡើងវិញត្រូវបានបង្កើត និងថែរក្សា។ សក្ខីកម្មក៏បានបង្ហាញថា "ខ្មាំង" ដែលត្រូវបានចោទប្រកាន់ត្រូវបានគេកម្ទេចពី "បទក្បត់អង្គការ"។ សក្ខីកម្មក៏បានបង្ហាញថា ប្រជាជនត្រូវបានគេចាប់ និង

---

[12] សូមអាន ឧទាហរណ៍ មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (*"ICCPR"*) មាត្រា៥នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប *("ECHR")*។

[13] ឯកសារតុលាការលេខ D91/29

សម្លាប់[14]តាមអំពើចិត្ត។ សក្ខីកម្មក៏បានបង្ហាញថា ប្រជាជនត្រូវបានគេបង្ខំឱ្យធ្វើការ[15]។ សក្ខីកម្មក៏បានបង្ហាញថា ព្រះសង្ឃត្រូវបានគេផ្សឹក[16]។ សក្ខីកម្មក៏បានបង្ហាញថា ប្រជាជនបានស្លាប់ដោយការអត់ឃ្លាន និងមិនបានទទួលការព្យាបាលវេជ្ជសាស្ត្រដ៏សមស្របទេ[17]។ សក្ខីកម្មក៏បានបង្ហាញថា ប្រជាជនត្រូវបានគេធ្វើទារុណកម្ម (រហូតដល់ស្លាប់)[18]។

ដោយជនត្រូវចោទគឺជាសមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលបានជួបប្រធានភូមិភាគ និងប្រធានតំបន់ជាទៀងទាត់[19] "ការស៊ើបសួរនានាតម្រូវឱ្យមានអ្នកសង្កេតការណ៍សត្យានុម័ត ម្នាក់ដែលអាចបញ្ជាក់ឱ្យគេជឿថា ជនត្រូវចោទអាចបានប្រព្រឹត្តបទល្មើសដូចដែលជននោះត្រូវបានគេចោទពិតប្រាកដមែន"។

២១. ការឃុំខ្លួន ដែលមានរយៈពេលវែងមិនអាចបង្កើតបានជាមូលហេតុល្អគ្រាប់គ្រាន់ដែលនឹងត្រូវចេញដីកាឱ្យមានការដោះលែងជាបណ្ដោះអាសន្នឡើយ[20] និងរឹតតែមិនមែនជាមូលហេតុដោះលែងទាល់តែសោះ ប្រសិនបើការស៊ើបអង្កេតត្រូវបានធ្វើឡើងដោយមិនពន្យាពេល និងជាមួយនឹងវីរិយភាពក្នុងករណីស្មុគស្មាញ (ដូចជាភាពស្មុគស្មាញបណ្ដាលមកពីអាកាសធាតុ និងលក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធ

---

[14] ឯកសារតុលាការលេខ D25/38; D40/18; D40

[15] ឯកសារតុលាការលេខ D94/20

[16] ឯកសារតុលាការលេខ D40/25

[17] ឯកសារតុលាការលេខ D40/18

[18] ឯកសារតុលាការលេខ D25/37

[19] ឯកសារតុលាការលេខ D107/2

[20] សូមមើល *ព្រះរាជអាជ្ញា* តតាំងជាមួយ *Casimir Bizimungu* et al.; TC II; ករណីលេខ: តុលាការ ICTR-99-50-T; ថ្ងៃទី៤ ខែ ឆ្នាំ២០០២, កថាខណ្ឌ៣១ និង *ព្រះរាជអាជ្ញា* តតាំងជាមួយ *Joseph Kanyabashi*; AC; ករណីលេខ. តុលាការ ICTR-96-15-A, កថាខណ្ឌ៣ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០១។

ពិសេសនៅកម្ពុជា ដូចជាក្នុងអំឡុងរដូវវស្សា ដែលមានការលំបាក ធ្វើដំណើរទៅទីតាំងឧក្រិដ្ឋកម្ម[21] ដោយសារផ្លូវថ្នល់ត្រូវលិចទឹកជាដើម ។

២២. ការពន្យាររយៈពេលឃុំខ្លួនបណ្តោះអាសន្នលើសមួយឆ្នាំ និងការពន្យាមួយឆ្នាំទៀត គឺនៅតែមានលក្ខណៈសមាមាត្រ និងសមហេតុផល[22] បើគិតអំពីបទល្មើសធ្ងន់ធ្ងររបស់ជនត្រូវចោទ និងបើប្រៀបធៀបទៅនឹងករណី[23]ផ្សេងៗទៀតនៃភាពស្មុគស្មាញបែបនេះ។

វិធាន៦៣ (៣) (ខ) នៃវិធានផ្ទៃក្នុង

២៣. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកត់សំគាល់ឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("CPC") ចែងថា សេរីភាពរបស់មនុស្សម្នាក់គឺជាច្បាប់ រីឯការឃុំខ្លួនគឺជាអញ្ញត្រកម្ម។ មាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងអំពីបុរេលក្ខខណ្ឌសម្រាប់ការឃុំខ្លួន គឺស្រដៀងគ្នានឹងវិធាន៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង។ សហមេធាវីសូមដាក់ជាសារណាថា អត្ថិភាពតែមួយគត់នៃ

---

[21] សូមមើលរបាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស; ឯកសារតុលាការ លេខ D25/37 ។

[22] ខ. ក្នុងករណី Bizimungu (សូមមើលជើងទំព័រ២០ វាមានរយៈពេលបីឆ្នាំនៅពេលចេញសេចក្តីសម្រេច) ។ ករណីអៀង សារី, សារណារួមរបស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨, ឯកសារតុលាការ លេខ.C22/I/35 ។

[23] សូមមើល *ព្រះរាជអាជ្ញា* តាំងជាមួយ *Coric et al.* TC III; ករណីលេខ: IT-04-74-T; សេចក្តីសម្រេច លើសំណើឲ្យការដោះលែងបណ្តោះអាសន្នដល់ជនជាប់ចោទ Coric, ថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៨, ដែលមានរយៈពេលជិតបីឆ្នាំនៃការឃុំខ្លួនបណ្តោះអាសន្នត្រូវបានចាត់ទុកថាសមាមាត្រ។ *ព្រះរាជអាជ្ញាតតាំងជាមួយ Mile Mrksic*; TC II; ករណីលេខ: IT-95-13/1-PT, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី សម្រាប់ការដោះលែងបណ្តោះអាសន្ន; ថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៥; ដែលអង្គជំនុំជម្រះបានសម្រេចឃុំខ្លួន អស់រយៈពេលពីរឆ្នាំ និងដប់ខែ; *ព្រះរាជអាជ្ញាតតាំងជាមួយ Dragomir Milosevic,*TC I; ករណីលេខ: IT-98-29/1-PT; សេចក្តីសម្រេចលើសំណើទីបីឲ្យមានការដោះលែងបណ្តោះអាសន្ន, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦; ដែលអង្គជំនុំជម្រះបានសម្រេចឲ្យជាប់ឃុំរយៈពេលមួយឆ្នាំ និងប្រាំបីខែមុនការជំនុំជម្រះ ។

បុរេលក្ខខណ្ឌ ទាំងនេះធ្វើឱ្យការឃុំខ្លួនបណ្តោះអាសន្ននេះមានយុត្តិកម្មសមរម្យ រួចស្រេចទៅហើយ។

ក) សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈរបស់ជនត្រូវចោទ

២៤. សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីប្រើប្រាស់ជាឯកសារយោង នូវសារណា ដែលមានក្នុងកថាខណ្ឌ៤៦ នៃចម្លើយតបនេះ[24] ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទ។

២៥. បន្ថែមលើនេះទៀត សំអាងហេតុថ្មីៗបានលេចឡើង។ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ បន្ទាប់ពីសវនាការលើបណ្តឹងឧទ្ធរណ៍របស់ខៀវ សំផន ដែលជាឧប្បត្តិហេតុមួយ រវាងអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីបាន កើតឡើងក្នុងអំឡុងសន្និសិទកាសែត ដែលតម្រូវឱ្យមានបទអន្តរាគមន៍ពីបុគ្គលិក សន្តិសុខរបស់សាលាក្តី[25]។

ព្រឹត្តិការណ៍នេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា សូម្បីតែមេធាវីការពារក្តីក៏ត្រូវ បានស្តីឱ្យចំៗដោយជនរងគ្រោះដែរ។ ដូច្នេះ យើងអាចសន្និដ្ឋានថា ការដោះលែង ជនត្រូវចោទអាចអុចអាលដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម។ បើទោះជា ការ ប៉ះទង្គិចគ្នានេះ មិនពាក់ព័ន្ធផ្ទាល់នឹងដើមបណ្តឹងឧទ្ធរណ៍នេះ និងមេធាវីការពារក្តី របស់គាត់ក្តីស្ថានភាពនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ អំពីភាពតានតឹងដែលមាន កម្រិតខ្ពស់នៅក្នុងសង្គមកម្ពុជា។ ព្រឹត្តិការណ៍នេះផ្តល់នូវភស្តុតាងថា ក្នុងករណី ដែលមានការដោះលែង សណ្តាប់ធ្នាប់ និងសុវត្ថិភាព ជនត្រូវចោទនឹងស្ថិតក្នុង ហានិភ័យ។

---

[24] ករណីអៀង សារី សារណារួមរបស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨, ឯកសារតុលាការ លេខ.C22/I/35 ។

[25] « សាលាក្តីខ្មែរក្រហម-សេចក្តីក្រេវក្រោធរបស់ជនរងគ្រោះបណ្តាលទៅជាការប៉ះទង្គិចគ្នាជាកាន់តែធ្ងន់ធ្ងរជាមួយក្រុមមេធាវីការពារក្តី-ដោយ Stéphanie Gée, ដកស្រង់ចេញពី http://ka-set.info/actualites/ khmers-rouges/cambodge-tribunal-victimes-khmer-rouge-defense-avocat-verges-co-procureurs-cetc-081205.html.

ខ) ការដាក់សម្ពាធមកលើសាក្សី និងការរក្សាភស្តុតាង ឬបង្អាការបំផ្លិតបំផ្លាញភស្តុតាង

២៦. ដីការបស់ក.ស.ច.ស គឺមានលក្ខណៈសមស្រប និងសមហេតុផល។ ដោយព្រោះថា ជនត្រូវចោទមានសិទ្ធិពេញលេញក្នុងការមើលសំណុំរឿង និងដឹងអំពីការអះអាងរបស់សាក្សី, ឈ្មោះ និងអាសយដ្ឋានពួកគេផង។ ហានិភ័យមានកំរិតខ្ពស់ដោយគាត់នឹងប្រើប្រាស់ឥទ្ធិពលរបស់គាត់ដោយខ្លួនគាត់ផ្ទាល់ ឬដោយតតិយភាគី ដើម្បី បង្អាសាក្សីទាំងអស់មិនឱ្យធ្វើសក្ខីកម្ម។

សេចក្តីសម្រេចរបស់ចៅក្រមមិនបង្ហាញពីការរំលោភឆន្ទានុសិទ្ធិឡើយ។ បន្ថែមលើនេះទៀត ដូចអង្គបុរេជំនុំជម្រះបានគ្រោងទុក ឥទ្ធិពលប្រកបដោយអំណាច និង អាជ្ញាធររបស់ជនត្រូវចោទនៅតែមានដដែលមកទល់ថ្ងៃនេះ[26]។

កាលៈទេសៈនៃការចុះចូលរបស់ជនត្រូវចោទក្នុងឆ្នាំ១៩៩៦ និងឥទ្ធិពលជាក់ស្តែងរបស់គាត់ទៅលើកងកម្លាំងប្រដាប់អាវុធខ្មែរក្រហម បង្ហាញអំពីអំណាចរបស់គាត់។ សកម្មភាព ដូចជាការសួរសុខទុក្ខយ៉ាងទៀងទាត់ទៅក្រុងប៉ៃលិនដើម្បីជួបមន្ត្រីរដ្ឋាភិបាល៣០រូប ដើម្បី "ប្រាប់" ពួកគេមិនឱ្យចូលរួមក្នុងចលនាប្រដាប់អាវុធ[27] បង្ហាញអំពីអំណាចខាងអាជ្ញាធររបស់គាត់នៅឡើយ។

បើទោះជាអង្គបុរេជំនុំជម្រះមិនអាចរកឃើញនូវភស្តុតាងជាក់លាក់ដែលជនត្រូវចោទបានប្រើប្រាស់អំណាចរបស់គាត់ក្តី ព្រឹត្តិការណ៍ថ្មីបានកើតឡើងរួចមកហើយ។

២៧. [បានលុបចោល]

---

[26] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ឱ្យឃុំខ្លួនលោក អៀង សារី ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ៨៧ និង ៨៨។

[27] "អៀង សារីពេញចិត្តនឹងតួនាទីផ្សះផ្សានៅកម្ពុជា" សារព័ត៌មាននយោបាយអាស៊ី ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០០។

២៨. [បានលុបចោល]

២៩. [បានលុបចោល]

៣០. ដូចស្ថាប័នផ្សេងៗ[28]បានសម្តែងថា គ្មាននីតិរដ្ឋ ឬប្រព័ន្ធតុលាការ ឬអាជ្ញាធរស៊ើប អង្កេតឯករាជ្យឡើយនៅប្រទេសកម្ពុជា។

ប្រសិនបើមានអ្វីមួយកើតឡើងចំពោះជនរងគ្រោះ ឬសាក្សីម្នាក់នោះ យើងមិន អាចរំពឹងថា ការស៊ើបអង្កេតណាមួយនឹងត្រូវបានធ្វើឡើងឲ្យបានត្រឹមត្រូវឡើយ។

គ) ហានិភ័យនៃការគេចខ្លួនតាមយន្តហោះ

៣១. សេចក្តីជំទាស់របស់មេធាវីការពារក្តីក្នុងករណីនេះបង្ហាញឲ្យឃើញថា គ្មានហេតុ ផលដែលត្រូវបដិសេធដីការបស់ ក.ស.ច.ស ឡើយ។ ការគាំទ្រដែលជនត្រូវ ចោទមាននៅក្រុងប៉ៃលិន អត្ថិភាពនៃមធ្យោបាយដោយយន្តហោះ និងតាមពិត ការជាប់ឃុំឃាំងមួយជីវិត ដែលគេបានរំពឹងទុក ប្រសិនត្រូវបានកាត់ទោសនោះ គឺជាមូលដ្ឋានដ៏សមហេតុផល ក្នុងការពិចារណាអំពីហានិភ័យនៃការគេចខ្លួន តាមយន្តហោះ។

ទឡ្ហីករណ៍ដែលថា ជនត្រូវចោទមិនបានរត់ភៀសខ្លួននោះ បើទោះជាគាត់បានដឹង អំពីការបង្កើត អ.វ.ត.ក ក៏ដោយនោះ មិនអាចចាត់ទុកជារឿងអស្ចារ្យអ្វីឡើយ។ ជនត្រូវចោទ ដែលបានទទួលព្រះរាជអនុគ្រោះទោស និងព្រះរាជលើកលែងទោស និងការគាំទ្រពីមេដឹកនាំរដ្ឋាភិបាល ដែលបានសម្តែងមតិ ថា លោក [អៀង សារី]

---

[28] របាយការណ៍គណៈកម្មាធិការសិទ្ធិមនុស្សអាស៊ី, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលសំដៅទៅលើ សេចក្តីថ្លែងការណ៍របស់តំណាងពិសេសអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស លោក Yash Ghai; សេចក្តីថ្លែងការណ៍រួមរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស និង អង្គការលើកលែងទោសអន្តរជាតិ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ ។ 'ម្ចាស់ជំនួសៈ សម្ពាធមិនមែនជាគន្លឹះចំពោះកំណែទម្រង់របស់រដ្ឋាភិបាលទេ' ដោយ លោក Tim Sturrock, សារព័ត៌មាន Cambodia Daily ចុះថ្ងៃទី៦-៧ ខែធ្នូ ឆ្នាំ២០០៨។

និងមិនត្រូវបានយកមកជំនុំជម្រះឡើយ ដោយយោងទៅតាមតួនាទីគន្លឹះរបស់គាត់ក្នុងការផ្តួចផ្តើម ការផ្សះផ្សាជាតិ និងស្វែងរកសន្តិភាព[29]។

ស្ថិតក្រោមកាលៈទេសៈទាំងនេះ ជនត្រូវចោទមិនត្រូវបានរំពឹងថាត្រូវបានឃុំខ្លួនឡើយ។

[29] 'ការជំនុំជម្រះលោក អៀង សារី របស់របបខ្មែរក្រហមអាចមានន័យថា សង្គ្រាមៈ ហ៊ុន សែន' សារព័ត៌មាននយោបាយអាស៊ី ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១។

**ការឃុំខ្លួនក្នុងផ្ទះ**

៣២. ការឃុំខ្លួនក្នុងផ្ទះក្រោមលក្ខខណ្ឌដាក់លាក់ទាំងនេះត្រូវបានធ្វើឡើងជាទម្រង់មួយនៃការឃុំខ្លួន បើទោះជាត្រូវបានពិចារណាថាមានភាពសម្រាលជាងការដាក់ក្នុងមន្ទីរឃុំឃាំង។ ទោះជាយ៉ាងណាក៏ដោយ ការឃុំខ្លួនក្នុងផ្ទះត្រូវធានាថា រាល់បុរេលក្ខខណ្ឌនៃវិធាន៦៣(៣)(ខ)ត្រូវបានបំពេញ ខ៣. ការឃុំខ្លួនក្នុងផ្ទះត្រូវបំពេញតាមតួនាទីដែលអាចប្រៀបធៀបបានមួយ ប្រៀបទៅនឹងមណ្ឌលឃុំឃាំងរបស់តុលាការ។

៣៣. បន្ទាប់ពីព្រឹត្តិការណ៍ថ្មីៗដូចបានលើកឡើងក្នុងកថាខណ្ឌ២២, ២៤ និង២៥ ការឃុំខ្លួនក្នុងផ្ទះមិនអាចធានានូវសុវត្ថិភាពរបស់ជនត្រូវចោទឡើយ ហើយសណ្តាប់ធ្នាប់សាធារណៈ ដែលអាចត្រូវបានរំខាន។

៣៤. ក្នុងករណីកម្រ ដែលជនត្រូវចោទត្រូវបានអនុញ្ញាតឱ្យស្ថិតក្នុងការឃុំខ្លួនក្នុងផ្ទះនៅតុលាការអន្តរជាតិផ្សេងៗទៀត[30] លក្ខខណ្ឌមួយនៃលក្ខខណ្ឌនានាគឺថា ជនត្រូវចោទត្រូវទទួលបន្ទុកចំណាយទាំងអស់ ពាក់ព័ន្ធនឹងកិច្ចការពារសន្តិសុខរបស់ខ្លួន ។

ប្រសិនបើជនត្រូវចោទ ត្រូវបានពិចារណាថា ខ្សត់ទុគ៌តនោះ ខ្លួនអាចគ្មានលទ្ធភាពចំណាយលើវិធានការសន្តិសុខសក្តានុពលសំខាន់ៗ។ សម្រាប់គោលបំណងនៃការឃុំខ្លួនក្នុងផ្ទះ ការវាយតម្លៃទ្រព្យសម្បត្តិគាត់គួរត្រូវបានពិនិត្យឡើងវិញ។

---

[30] សូមមើលតែ *ព្រះរាជអាជ្ញា* តតាំងជាមួយ*Blaskic*, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីដែលបានដាក់ អនុឡោមទៅតាមវិធាន៦៤នៃបទដ្ឋាននីតិវិធី និងភស្តុតាង, ករណីលេខ. IT-94-14-T, កថាខណ្ឌ២៤; Blaskic បានសារៈភាពដោយស្ម័គ្រចិត្ត ខណៈដែលអាជ្ញាធរក្រូអាទីមិនទាន់ទាំងមានមធ្យោបាយផ្លូវច្បាប់ណាមួយ ដែលចាំបាច់ក្នុងការបញ្ជូនអ្នកទោសទៅតុលាការ ICTY ផង។

## VI. សេចក្តីសន្និដ្ឋាន

៣៥. បណ្តឹងឧទ្ធរណ៍នេះត្រូវតែទាត់ចោល។ ដីកាពន្យាការឃុំខ្លួនរបស់ក.ស.ច.សគឺសមហេតុផល និងមានយុត្តិកម្ម ហើយការប្រើប្រាស់ឆន្ទានុសិទ្ធិត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ។

**ដោយមូលហេតុនេះ**

សូមអង្គបុរេជំនុំជម្រះមេត្តាបដិសេធបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីចោល។

សូមដាក់ជូនដោយសេចក្តីគោរពអំពីយើងខ្ញុំ។

សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី

**ហុង គឹមសួន**
មេធាវីមកពីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

**ឡោ ជុនធី**
មេធាវីមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

**ទី ចាន់ឌី**
មេធាវីមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

**គង់ ពិសី**
មេធាវីមកពីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

**យុង ផានិត**

មេធាវីមកពីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

**Silke Studzinsky**

មេធាវី

**គឹម ម៉េង ឃី**

មេធាវីមកពី avocats sans frontières

**ម៉ុច សុវណ្ណារី**

មេធាវីមកពី avocats sans frontiers

**Martine Jacquin**

មេធាវីមកពី avocats sans frontières

**Philippe Cannone**

មេធាវីមកពី avocats sans frontières

ធ្វើនៅភ្នំពេញ

ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨

ចម្លើយតបរបស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងឧទ្ធរណ៍របស់
លោក អៀង សារីប្រឆាំងនឹងការពន្យាការឃុំខ្លួនបណ្តោះអាសន្ន